ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

លេខ ០១៥ ឈ.ណន-ទគស.កគ៩

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១២

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច និងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ហើយដែលស្ថិតនៅក្នុងតំបន់ដីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋដែលមានដីកាដកហូតដោយអាជ្ញាធរខេត្ត ព្រមទាំងរក្សាការពារធនធានធម្មជាតិឲ្យបានល្អប្រសើរ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លីសូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមានដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត ទាក់ទងនឹងដីរបស់សហគមន៍ជនជាតិដើមភាគតិចនិងដីដែលស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ដូចតទៅ៖

## I- <u>ដីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ</u>

### ១. សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនីតិបុគ្គលរួចហើយ នៅក្រសួងមហាផ្ទៃ:

- ត្រូវដំណើរការធ្វើអត្តសញ្ញាណកម្មដី តាមស្មារតីការងារដូចបានកំណត់ក្នុងឯកសារដែលអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្របានណែនាំទាក់ទងនឹងដំណើរការនៃការអនុវត្តបទបញ្ជាលេខ ០១.បប និងត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ តាមការស្នើសុំរបស់អាជ្ញាធរប្រពៃណី ឬប្រធានគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ទៅតាមប្រភេទនិងទំហំដីដូចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។



អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ

- ក្រោយពីការធ្វើអត្តសញ្ញាណកម្មនិងអនុវត្តតាមជំហានការងារខាងលើរួច ត្រូវចេញ**ប័ណ្ណកម្មសិទ្ធិបឋម**ជូនសហគមន៍ ដោយមានភ្ជាប់ជាមួយនូវផែនទីបឋមដែលសម្គាល់ពីទីតាំងនិងប្រភេទដីរបស់សហគមន៍។

- នៅលើប័ណ្ណកម្មសិទ្ធិបឋម៖

» ត្រង់ចំណុច II.**អត្តសញ្ញាណអ្នកកាន់កាប់ដី៖** ត្រូវសរសេរឈ្មោះសហគមន៍ជនជាតិដើមភាគតិចដែលកាន់កាប់ដីនោះ *(ឧទាហរណ៍: **II. អត្តសញ្ញាណអ្នកកាន់កាប់ដី៖ សហគមន៍ជនជាតិដើមភាគតិចទំពួន )*** ភូមិ......... ឃុំ......... ស្រុក ....... ខេត្ត...........។

» ត្រង់ចំណុច III.**ប្រភេទទ្រព្យ៖**....... ត្រូវសរសេរ **កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច.....នៃភូមិ...***(ឧទាហរណ៍: III. **ប្រភេទទ្រព្យ៖ កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទំពួននៃភូមិឡាអិន**)*។

- នៅពេលចេញប័ណ្ណកម្មសិទ្ធិស្ថាពរ ត្រូវចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងចេញប័ណ្ណកម្មសិទ្ធិសមូហភាព តាមស្មារតីនៃអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

**២. ចំពោះសហគមន៍ដែលកំពុងដំណើរការសុំចុះបញ្ជីសហគមន៍នៅក្រសួងមហាផ្ទៃជានីតិបុគ្គល** ត្រូវអនុវត្តដូចគ្នានឹងសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជានីតិបុគ្គលរួចហើយនៅក្រសួងមហាផ្ទៃដែរ។

**៣. ចំពោះជនជាតិដើមភាគតិចដែលមិនចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាឯកជន** ត្រូវអនុវត្តដូចប្រជាពលរដ្ឋកម្ពុជាទូទៅដែរ ដោយទទួលបានដីជាកម្មសិទ្ធិឯកជន លើចំណែកដីដែលគាត់បាននិងកំពុងកាប់កាប់និងដាំដុះជាក់ស្តែងតែប៉ុណ្ណោះ។ ក្នុងករណីនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវលើកសំណើសុំធ្វើអនុបយោគ ប្រសិនបើដីនោះជាដីសាធារណៈរបស់រដ្ឋ។

## II- <u>ដីក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ</u>

ក្នុងដំណើរការធ្វើអត្តសញ្ញាណកម្ម ប្រសិនបើមានប្រជាពលរដ្ឋមកអះអាង និង/ឬមានការស្នើសុំសិទ្ធិលើចំណែកដីដែលស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ការអះអាងនិងការទាមទារទាំងនោះនឹងមិនត្រូវយកមកពិនិត្យឡើយ។

ចំណែកដីដែលពាក់ព័ន្ធនឹងកិច្ចសន្យាណាមួយ ហើយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបានធ្វើអត្តសញ្ញាណកម្មឃើញថាជាដីស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវលើកសំណើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល។

សេចក្ដីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

***ចម្លងជូន៖***

- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
- *ឯកសារ កាលប្បវត្តិ*